**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី៣៥)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៨ ១០៧ នាក់ នៃរោងចក្រ សហគ្រាស ទាំង៣០ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារឯកទេសវីង នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរស័ព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួន៖

- ៦០ ៧៥០រៀល (១៥ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២១ ៥០០រៀល (៣០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។ សូមបញ្ជាក់ថា សម្រាប់បងប្អូនដែលព្យួរកិច្ចសន្យាការងាររយៈពេល ២ខែ ប្រាក់ឧបត្ថម្ភនឹងត្រូវបើកជា ២លើក ដោយលើកទី២ នឹងបើកនៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២០។

ក្រសួងសូមរំឮកថា ធនាគារឯកទេសវីង នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខានមិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរស័ព្ទពីធនាគារឯកទេសវីង។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរស័ព្ទដែលទទួលបានសារនោះទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាស ទាំង៣០ នេះ មិនបានទទួលសារទូរស័ព្ទពីធនាគារឯកទេសវីង នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ ព្រហស្បតិ៍ ១២កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ២០២០

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

### ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០

### បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ ចំនួន ៣០ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 15 |
| 1 | ក្រុមហ៊ុន ថេកអូហ្ (ខេមបូឌា) | ភ្នំពេញ |
| 2 | ក្រុមហ៊ុន អ៊ីអឹមប៊ី ដែលកូរី (ខេមបូឌា)ខូ.,អិលធីឌី | ភ្នំពេញ |
| 3 | ក្រុមហ៊ុន សានស៊ូ ខ្លូស៊ីង (ខេមបូឌា)ឯ.ក | ភ្នំពេញ |
| 4 | ក្រុមហ៊ុន យើង ហ្វេសិន ហ្គាមេន | ភ្នំពេញ |
| 5 | ក្រុមហ៊ុន វើហ៊្វុល ហ្គាមេន (ខេមបូឌា) អិលធីឌី | កណ្តាល |
| 6 | ក្រុមហ៊ុន គ្លូរី នីត វែរ អិលធីឌី | កណ្តាល |
| 7 | ក្រុមហ៊ុន យ៉ូនធ័ មេដើរ អ៊ិនដាសស្រៀល | កណ្តាល |
| 8 | ក្រុមហ៊ុន វ៉ាយ អិម ជី ហ្គាមេន អេកសេសើរី | កណ្តាល |
| 9 | ក្រុមហ៊ុន ដា រ៉ុង ព្រីនធីង & អឹមប្រយឌើរី | កណ្តាល |
| 10 | ក្រុមហ៊ុន ញូអាកឃីត ហ្គាមេន ហ្វេកធើរី លីមីតធីត | កណ្តាល |
| 11 | ក្រុមហ៊ុន ស៊ីគ្លូ (ខេមបូឌា)ឯ.ក | កំពង់ស្ពឺ |
| 12 | ក្រុមហ៊ុន ស៊ូគៀល (ខេមបូឌា)ឯ.ក | កំពង់ស្ពឺ |
| 13 | ក្រុមហ៊ុន អេស យ៉ែន (ខេមបូឌា)អឹមភែរីល មេនូហ្វេកឆឺរីង | កំពង់ស្ពឺ |
| 14 | ក្រុមហ៊ុន ប្រាយ ហ្វ្លាស់ស៊ីង ឯ.ក | តាកែវ |
| 15 | ក្រុមហ៊ុន តើហ្សិក វីសិន ហ្វេសិន ( ខេមបូឌា) ឯ.ក | តាកែវ |
| ខ. វិស័យទេសចរណ៍ | | 15 |
| 16 | ក្រុមហ៊ុន ដារ៉ា អ៊ែរផត ហូថេល | ភ្នំពេញ |
| 17 | សណ្ឋាគារ រ៉ាហ្វិលរ៉ូយ៉ាល់ | ភ្នំពេញ |
| 18 | ក្រុមហ៊ុន តូយ៉ូកូ អ៊ីន (ខេមបូឌា) | ភ្នំពេញ |

| ល.រ | ឈ្មោះភោជនីយដ្ឋាន សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 19 | ក្រុមហ៊ុន វីណា ហុងកុង ខំផែនី អែលធីឌី | ភ្នំពេញ |
| 20 | សណ្ឋាគារ អូឡាំព្យា ស៊ីធី ហូថេល | ភ្នំពេញ |
| 21 | ក្រុមហ៊ុន កូបេ យៃកែននីស រេស្តូរ៉ង់ | សៀមរាប |
| 22 | ភោជនីយដ្ឋាន វីវ៉ា | សៀមរាប |
| 23 | ក្រុមហ៊ុន អេច ឌី រ៉ក កាហ្វេ & សប | សៀមរាប |
| 24 | ក្រុមហ៊ុន ដឹ សុទ្ធា (ខេ.វី) ភីធីអ៊ី អិលធីឌី | សៀមរាប |
| 25 | ក្រុមហ៊ុន ហ្វូដ អេន បេវើរិច សឺលូសិន | សៀមរាប |
| 26 | ក្រុមហ៊ុន អញ្ចលី បាយ ស៊ីផុន | សៀមរាប |
| 27 | ក្រុមហ៊ុន ដឹ អេវៀរី | សៀមរាប |
| 28 | ក្រុមហ៊ុន ម៉ុនស៊ូន អេស៊ាន ប៊ីស្ត្រ | សៀមរាប |
| 29 | ភោជនីយដ្ឋាន ហាទៀន វីហ្គាស | កំពត |
| 30 | ក្រុមហ៊ុន ប្រូខន អ៊ិនវេសមេន ខូ អិលធីឌី | ព្រះសីហនុ |